ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ស្ថាប័នអយ្យការយោធា

លេខ...០៤៤/៩៩

# ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ

- យើងឧត្តមសេនីយ៍ទោ សាវ សុខ ព្រះរាជអាជ្ញាយោធា

- បានឃើញច្បាប់ ស្តីពីការចាត់តាំងនិងសកម្មភាពសាលាជំរះក្តី នៃរដ្ឋកម្ពុជា. ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៣

- បានឃើញមាត្រា ១៥៨ ថ្មី ដែលបានចែងថា: ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបានទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់ របស់បុគ្គល និង ដែលសមស្រប និង ប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនិងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

- ច្បាប់រដ្ឋធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី២ ។

- បានឃើញច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩ ។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបទល្មើសថ្មីបន្ថែមរបស់ចៅក្រមស៊ើបអង្កេតលេខ ១៦២/៩៩ឯក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៩ ។

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩ និង សំរេចចោទប្រកាន់ :

១/ ឈ្មោះ អ៊ុំ ឈឿន ហៅតា មុំក ភេទប្រុស

- កើតនៅថ្ងៃមិនចាំ ខែមិនចាំ ឆ្នាំខាល (១៩២៧)
- នៅភូមិប្រកៀប ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។
- បច្ចុប្បន្ន : ផ្ទះកណ្តាល (ជាំ) ព្រំប្រទល់កម្ពុជា-ថៃ ។
- ចូលទ័ព ឆ្នាំ ១៩៤៥ សញ្ជាតិកម្ពុជា ជនជាតិខ្មែរ សាសនាព្រះពុទ្ធ

- ប្រពន្ធឈ្មោះ រី ពោន អាយុ ៤០ឆ្នាំ ជនជាតិខ្មែរ [illegible] សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ ។
- ស្រុកកំណើត៖ ភូមិព្រៃខ្លា ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ ។
- ទីលំនៅបច្ចុប្បន្ន : ផ្ទះកណ្តាល (ជាំ) ព្រំដែនកម្ពុជា-ថៃ
- មានកូន ៧ នាក់ : ប្រុស ១នាក់ ស្រី ៦នាក់ ។

២/ ឈ្មោះ **គាំខ ហ្គេកអ៊ាវ ហៅតា ឌុច** ភេទប្រុស

- កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២
- កើតនៅភូមិពៅរ៉ើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។
- បច្ចុប្បន្ន : ភូមិអូរទន្ទឹម ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង ។
- សញ្ជាតិកម្ពុជា ជនជាតិខ្មែរ សាសនាគ្រិស្ត
- មុខរបរ គ្រូបង្រៀន និង ប្រធានគុកទួលស្លែង (សម័យប៉ុលពត) ។
- ប្រពន្ធឈ្មោះ ឈឹម សុផល កើតឆ្នាំ ១៩៤៦ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ
- ស្រុកកំណើត ភូមិហុងឡោត ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
- ទីលំនៅបច្ចុប្បន្ន : (ស្លាប់)
- មានកូន ៤នាក់ : ប្រុស ៣នាក់ ស្រី ០១នាក់

__ពិរុទ្ធ:__ ឧក្រិដ្ឋប្រល័យពូជសាសន៍ ។

បំពានលើមាត្រាទី២ នៃក្រឹត្យច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩ ។

ប្រព្រឹត្តិនៅកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បញ្ជូនសំណុំរឿងនិងជនល្មើស ទៅចៅក្រម ស៊ើបសួរដើម្បីចាត់ការតាមច្បាប់និតិវិធីព្រហ្មទណ្ឌជាធរមាន និងសុំឃុំខ្លួនជនល្មើសជាបណ្តោះអាសន្ន ។

ធ្វើនៅថ្ងៃទី...06...ខែ...09...ឆ្នាំ...1999

ព្រះរាជអាជ្ញា_យោធា

ឧត្តមសេនីយ៍ទោ សាវ_សុខ